# ឈរក្នុងកន្លែងដ៏បរិសុទ្ធ

*ដោយប្រធាន ថូម៉ាស អេស ម៉នសុន*

បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំ យើងបានស្ដាប់ឮសារលិខិតដ៏ល្អៗជាច្រើននាព្រឹកនេះ ហើយខ្ញុំសូមសរសើរដល់បុគ្គលម្នាក់ៗដែលបានចូលរួម ។ ជាពិសេសយើងរីករាយជាខ្លាំង ដោយមានវត្តមានរបស់ អែលឌើរ រ៉ូបឺត ឌី ហែល នៅជាមួយយើងជាថ្មីម្ដងទៀត ហើយមានសុខភាពល្អប្រសើរឡើងវិញ ។ យើងស្រឡាញ់លោក បប ។

ពេលខ្ញុំពិចារណាពីអ្វីដែលខ្ញុំចង់និយាយទៅកាន់អ្នករាល់គ្នានាព្រឹកនេះ ខ្ញុំមានអារម្មណ៍ឲ្យចែកចាយនូវគំនិត និងអារម្មណ៍ដ៏ជាក់លាក់មួយចំនួន ដែលខ្ញុំចាត់ទុកថា ជារឿងដ៏សំខាន់ ហើយចំពេល ។ ខ្ញុំសូមអធិស្ឋានថា ខ្ញុំនឹងត្រូវបានដឹកនាំក្នុងការនិយាយរបស់ខ្ញុំ ។

ឥឡូវនេះ ខ្ញុំបានរស់នៅលើផែនដីនេះ អស់រយៈពេល 84 ឆ្នាំហើយ ។ ដើម្បីផ្ដល់ឲ្យអ្នកនូវទិដ្ឋភាពទូទៅតូចមួយ ខ្ញុំកើតនៅឆ្នាំដែលឆាលឡេស លីនបើហ្គ បានបើកយន្តហោះមិនឈប់តែម្នាក់ឯងដំបូងគេបង្អស់ ពីរដ្ឋ នូវយោក ទៅទីក្រុងប៉ារីស តាមយន្តហោះដែលមានម៉ាស៊ីនមួយ និងកៅអីមួយ ។ ចាប់ពីពេលនោះមក មានរឿងជាច្រើនបានផ្លាស់ប្ដូរអំឡុងពេល 84 ឆ្នាំនេះ ។ ឥឡូវនេះ វាមានរយៈពេលយូរហើយ ចាប់តាំងពីមនុស្សបានធ្វើដំណើរទៅកាន់ភពព្រះចន្ទ ហើយត្រឡប់មកវិញ ។ ពិតណាស់ រឿងប្រឌិតដែលវិទ្យាសាស្ត្របានធ្វើឡើងកាលពីមុន ឥឡូវនេះបានក្លាយជាការពិត ។ ហើយសូមអរគុណដល់បច្ចេកវិជ្ជានៃជំនាន់យើង ដែលការពិតនៅកំពុងតែផ្លាស់ប្ដូរយ៉ាងលឿន ដែលយើងស្ទើរតែដើរតាមមិនទាន់ ។ ចំពោះអស់អ្នកណាដែលនៅចាំពីទូរស័ព្ទរវៃ និងម៉ាស៊ីនអង្គុលីលេខ បច្ចេកវិជ្ជានៅសព្វថ្ងៃនេះ គឺអស្ចារ្យជាងនេះទៅទៀត ។

បទដ្ឋានខាងសីលធម៌ក្នុងសង្គមក៏មានការផ្លាស់ប្ដូរយ៉ាងលឿនផងដែរ ។ ឥរិយាបថដែលត្រូវបានចាត់ទុកថាមិនសមរម្យ ហើយអសីលធម៌នៅគ្រាមួយ ឥឡូវនេះមិនគ្រាន់តែត្រូវបានគេទទួលយកប៉ុណ្ណោះទេ តែក៏ត្រូវបានទទួលយកដោយមនុស្សជាច្រើនផងដែរ ។

ថ្មីៗនេះ ខ្ញុំបានអានអត្ថបទមួយអំពីគ្រូសាសនាយូដារបស់អង់គ្លេស ដោយ យូណាថាន សាក ក្នុងសារព័ត៌មាន *Wall Street Journal* ។ គាត់បានសរសេររឿងជាច្រើន ---ហើយខ្ញុំសូមដកស្រង់ថា ៖ « នៅស្ទើរតែគ្រប់សង្គមលោកខាងលិចនាឆ្នាំ 1960 មានការផ្លាស់ប្ដូរទាំងស្រុងមួយខាងសីលធម៌ ដែលជាការបោះបង់ចោលនូវច្បាប់ដែលមនុស្ស គប្បីឃុំគ្រងឥរិយាបថខ្លួន ។ ក្រុមចម្រៀង ប៊ីអាថល ច្រៀងចម្រៀងបទ អ្វីដែលអ្នកត្រូវការ គឺក្ដីស្រឡាញ់ ។ បទដ្ឋានសីលធម៌របស់យូដា និងគ្រីស្ទានត្រូវបានគេបោះបង់ចោល ។ ក្នុងបទដ្ឋាននោះ មានពាក្យមួយឃ្លាថែងថា ៖ ធ្វើនូវអ្វីៗដែលនាំប្រយោជន៍ដល់អ្នក ។ ក្រឹត្យវិន័យដប់ប្រការត្រូវបានគេសរសេរឡើងវិញ ជាសេចក្ដីណែនាំដើមទាំងដប់ » ។

រ៉ាប៊ី សាក បានបន្តត្អូញត្អែរថា ៖ « យើងបានបោះបង់គោលការណ៍សីលធម៌របស់យើងចោលដោយមិនខ្វល់ខ្វាយ គឺប្រៀបដូចជាយើងបានបោះបង់ធនធានហិរញ្ញវត្ថុរបស់យើងចោលដែរ ... ។ មានផ្នែកដ៏ធំជាច្រើននៃពិភពលោកនេះ ដែលសាសនា គឺជារឿងអតីតកាល ហើយគ្មានសម្លេងការពារណាមួយចំពោះគំនិតវប្បធម៌ដែលជំរុញមនុស្សឲ្យទិញរបស់ ចំណាយប្រាក់ ស្លៀកសំលៀកបំពាក់ឆើតឆាយ ហើយសម្ដែង នូវឬកពាររបស់ខ្លួនឡើយ ។ សារលិខិតនេះ គឺមានន័យថា ចរិយាធម៌ គឺជារឿងហួសសម័យ ការមានមនសិការ គឺសម្រាប់តែមនុស្សទន់ខ្សោយ ហើយបញ្ញត្តិដ៏សំខាន់បំផុត គឺ ‹ បើធ្វើបាបកុំឲ្យគេដឹង › » ។ [1]

បងប្អូនប្រុសស្រីរបស់ខ្ញុំ ជាអកុសល---ការណ៍នេះ---រៀបរាប់ពីផ្នែកជាច្រើននៃពិភពលោកជុំវិញយើង ។ តើយើងត្រូវបារម្ភទាំងអស់សង្ឃឹម ហើយងឿងឆ្ងល់ថា តើយើងនឹងអាចបន្តរស់នៅក្នុងពិភពលោកមួយបែបនេះបានដោយរបៀបណាមែនទេ ? ទេ ។ ពិតណាស់ យើងមានដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទក្នុងជីវិតយើង ហើយយើងដឹងថា ចរិយាធម៌ គឺមិនហួសសម័យឡើយ ថាយើងមានមនសិការរបស់យើង ដើម្បីដឹកនាំយើង ហើយថាយើងទទួលខុសត្រូវ ចំពោះទង្វើយើង ។

ទោះបីពិភពលោកនេះផ្លាស់ប្ដូរក្ដី ក៏ក្រឹត្យវិន័យនៃព្រះនៅតែគង់វង្សស្ថិតស្ថេរ ។ វាមិនបានផ្លាស់ប្ដូរ ហើយនឹងមិនផ្លាស់ប្ដូរឡើយ ។ ក្រឹត្យវិន័យដប់ប្រការគឺជា---ក្រឹត្យវិន័យទាំងឡាយ ។ វាពុំមែន ជាសេចក្ដីណែនាំឡើយ ។ វាចាំបាច់នៅសព្វថ្ងៃនេះ ដូចគ្នានឹងពេលដែលព្រះបានប្រទានដល់កូនចៅអ៊ីស្រាអែលផងដែរ ។ បើយើងស្ដាប់ យើងនឹងឮសូររំពងនៃព្រះសូរសៀងនៃព្រះ ដោយមានបន្ទូលមកកាន់យើងនាពេលនេះថា ៖

« កុំឲ្យមានព្រះឯណាទៀតនៅចំពោះយើងឲ្យសោះ ។

កុំឲ្យឆ្លាក់ធ្វើរូបណាសម្រាប់អ្នកឲ្យសោះ ... ។
កុំឲ្យចេញព្រះនាមរបស់ព្រះអម្ចាស់ជាព្រះនៃអ្នកជាអសារឥតការឡើយ ... ។
ចូរឲ្យនឹកចាំពីថ្ងៃឈប់សម្រាក ដើម្បីថ្ងៃនោះចេញជាបរិសុទ្ធ ... ។
ចូរឲ្យគោរពប្រតិបត្តិដល់ឪពុកម្ដាយ ... ។
កុំឲ្យសម្លាប់មនុស្សឲ្យសោះ ។
កុំឲ្យកំផិតគ្នាឲ្យសោះ ។
កុំឲ្យលួចប្លន់ឲ្យសោះ ។
កុំឲ្យធ្វើជាទីបន្ទាល់ក្លែង ... ។
កុំឲ្យលោភចង់បាន » ។ [2]

ឥរិយាបថយើងមានភាពច្បាស់លាស់ វាមិនអាចផ្លាស់ប្ដូរបានឡើយ ។ វាមិនគ្រាន់តែមាននៅក្នុងក្រឹត្យវិន័យដប់ប្រកាសប៉ុណ្ណោះទេ តែក៏មានក្នុងការបង្រៀនលើភ្នំ ដែលព្រះអង្គសង្គ្រោះបានប្រទានឲ្យយើង ពេលទ្រង់នៅលើផែនដីនេះ ។ វាមានក្នុងការបង្រៀនទ្រង់ ។ វាមានក្នុងព្រះបន្ទូលនៃវិវរណៈសម័យទំនើប ។

ព្រះវរបិតា គង់នៅស្ថានសួគ៌យើង គឺនៅតែដដែលកាលពីម្សិលមិញ ថ្ងៃនេះ និងរហូតតទៅ ។ ព្យាការីមរមនបានប្រាប់យើងថា ព្រះ « ទ្រង់ពិតជាឥតប្រែប្រួលតាំងពីភាពអស់កល្បជានិច្ចទៅភាពអស់កល្បជានិច្ច ។ [3] ក្នុងពិភពលោកនេះ អ្វីៗគ្រប់យ៉ាងហាក់ដូចជាកំពុងផ្លាស់ប្ដូរ ភាពស្មោះត្រង់ទ្រង់ គឺជាអ្វីមួយដែលយើងអាចពឹងផ្អែក ជាយុថ្កាមួយដែលយើងអាចតោង ហើយមានសុវត្ថិភាព ដើម្បីកុំឲ្យយើងបក់បោកចូលទៅក្នុងទន្លេដែលមិនស្គាល់ ។

ពេលខ្លះអ្នកឃើញថា អស់អ្នកដែលនៅក្នុងលោកិយកំពុងមានភាពសប្បាយរីករាយជាងអ្នក ។ អ្នករាល់គ្នាមួយចំនួន អាចមានអារម្មណ៍តឹងតែងចំពោះបទដ្ឋាននៃឥរិយាបថ ដែលយើងមានក្នុងសាសនាចក្រនេះ ។ ប៉ុន្តែ បងប្អូនប្រុសស្រីរបស់ខ្ញុំ ខ្ញុំសូមប្រកាសប្រាប់អ្នកថា គ្មានអ្វីដែលអាចនាំមកនូវក្ដីអំណរក្នុងជីវិតយើង ឬក្ដីសុខសាន្តក្នុងព្រលឹងយើងជាងព្រះវិញ្ញាណដែលកើតមានចំពោះយើង ពេលយើងធ្វើតាមព្រះអង្គសង្គ្រោះ និងគោរពព្រះបញ្ញត្តិនោះទេ ។ ព្រះវិញ្ញាណនោះមិនអាចមានវត្តមាននៅក្នុងសកម្មភាពដែលមានរឿងខាងលោកិយច្រើនពេកនោះឡើយ ។ សាវកប៉ុលបានប្រកាសពីសេចក្ដីពិតនេះថា ៖

« មនុស្សខាងសាច់ឈាម គេមិនទទួលសេចក្ដីខាងឯព្រះវិញ្ញាណនៃព្រះទេ ពីព្រោះជាសេចក្ដីល្ងង់ល្ងើដល់គេ ក៏រកស្គាល់មិនបានដែរ ត្បិតគ្រង់ឯសេចក្ដីទាំងនោះ ត្រូវពិចារណាយល់ខាងវិញ្ញាណវិញ » ។ [4] ពាក្យថា « មនុស្សខាងសាច់ឈាម » អាចសំដៅទៅលើយើងរាល់គ្នា បើយើងបណ្ដោយខ្លួនឲ្យធ្វើជាមនុស្សបែបនោះ ។ យើងត្រូវមានការប្រុងប្រយ័ត្នក្នុងពិភពលោកមួយ ដែលរំកិលចេញយ៉ាងឆ្ងាយពីអ្វីដែលជារឿងខាងវិញ្ញាណ ។ វាជាការចាំបាច់ថា យើងត្រូវបដិសេធរាល់អ្វីទាំងអស់ដែលមិនសមស្របទៅនឹងបទដ្ឋានរបស់យើង ដោយបដិសេធចំពោះដំណើរការដើម្បីបោះបង់ចោលនូវអ្វីដែលយើងប្រាថ្នាចង់បានបំផុត ---ជាជីវិតអស់កល្បក្នុងនគរព្រះ ។ ព្យុះភ្លៀងទាំងឡាយនឹងនៅតែបោកបក់មកលើមាត់ទ្វាររបស់យើងម្ដងហើយម្ដងទៀត ត្បិតវាជាផ្នែកមួយ ដែលមិនអាចគេចវេសបាននៅក្នុងជីវិតរមែងស្លាប់យើង ។ តែយើងនឹងមានការរៀបចំខ្លួនកាន់តែប្រសើរឡើង ដើម្បីប្រឈមមុខនឹងវា ដើម្បីរៀនពីវា និងដើម្បីយកឈ្នះលើវា បើយើងមានដំណឹងល្អធ្វើជាគ្រឹះនៃជីវិតយើង និងមានក្ដីស្រឡាញ់នៃព្រះអង្គសង្គ្រោះក្នុងដួងចិត្តយើង ។ ព្យាការីអេសាយបានប្រកាសថា « ការនៃសេចក្ដីសុចរិត នោះនឹងបានជាសន្តិសុខ ហើយផលនៃសេចក្ដីសុចរិត នោះនឹងបានជាសេចក្ដីស្រាកស្រាន្ត និងជាសេចក្ដីទុកចិត្តជាដរាបតទៅ » ។ [5]

ក្នុងនាមជាមធ្យោបាយមួយនៃការរស់នៅក្នុងលោកិយ តែមិនមែនជារបស់ផងលោកិយ វាចាំបាច់ថាយើងត្រូវទំនាក់ទំនងនឹងព្រះវរបិតាសួគ៌យើងដោយការអធិស្ឋាន ។ ទ្រង់ចង់ឲ្យយើងធ្វើបែបនេះ ទ្រង់នឹងឆ្លើយចំពោះការអធិស្ឋានយើង ។ ព្រះអង្គសង្គ្រោះបានទូន្មានយើង ដូចដែលបានកត់ត្រាក្នុងនីហ្វៃទី3 ជំពូកទី 18 ឲ្យ « ចាំយាម ហើយអធិស្ឋានជានិច្ច ខ្លាចក្រែងអ្នកធ្លាក់ទៅក្នុងសេចក្ដីល្បួង ត្បិតអារក្សសាតាំងមានបំណងចង់បានអ្នករាល់គ្នា ... ។

« ដូច្នេះ អ្នករាល់គ្នាត្រូវអធិស្ឋានដល់ព្រះវរបិតាដោយនូវព្រះនាមយើងជានិច្ច ហើយសូម្បីជាអ្វីដែលអ្នករាល់គ្នាសុំព្រះវរបិតាដោយនូវព្រះនាមយើងដែលត្រឹមត្រូវ និងដោយជឿថា អ្នកនឹងបានទទួល មើលចុះនឹងបានប្រទានដល់អ្នក » ។ [6]

ខ្ញុំបានទទួលទីបន្ទាល់ខ្ញុំពីអំណាចនៃការអធិស្ឋាន ពេលខ្ញុំមានអាយុប្រហែលជា 12 ឆ្នាំ ។ ខ្ញុំបានខិតខំធ្វើការដើម្បីរកប្រាក់មួយចំនួន ហើយបានចាត់ចែងដើម្បីសន្សំទុកប្រាក់ប្រាំដុល្លារ ។ នេះស្ថិតនៅក្នុងគ្រានៃវិបត្តិសេដ្ឋកិច្ចដ៏ធំ ជាពេលដែលប្រាក់ប្រាំដុល្លារជាចំនួនប្រាក់ដ៏ច្រើន ---ជាពិសេស

សម្រាប់ក្មេងប្រុសអាយុ 12 ឆ្នាំ ។ ខ្ញុំបានឲ្យកាក់របស់ខ្ញុំទាំងអស់ ដែលមានចំនួនប្រាំដុល្លារ ទៅឪពុកខ្ញុំ ហើយគាត់បានឲ្យមកខ្ញុំវិញជាក្រដាសប្រាក់ប្រាំដុល្លារ ។ ខ្ញុំដឹងថា មាននូវអ្វីមួយជាក់លាក់ដែលខ្ញុំបានរៀបចំដើម្បីទិញជាមួយនឹងប្រាក់ប្រាំដុល្លានោះ ទោះបីជាឥឡូវនេះខ្ញុំមិនអាចនឹកឃើញវាក៏ដោយ ។ ខ្ញុំគ្រាន់តែចាំថា ប្រាក់នោះមានតម្លៃសម្រាប់ខ្ញុំខ្លាំងណាស់ ។

នៅពេលនោះយើងពុំទាន់មានម៉ាស៊ីនបោកខោអាវនៅឡើយ ដូច្នេះម្ដាយខ្ញុំបានយកខោអាវដែលត្រូវបោកគក់ទៅកន្លែងបោកអ៊ុតជារៀងរាល់សប្តាហ៍ ។ លុះប៉ុន្មានថ្ងៃក្រោយមក ពំនូកនៃអ្វីដែលយើងថា « ខោអាវទទឹក » បានបញ្ជូនត្រឡប់មកយើងវិញ ហើយម្ដាយខ្ញុំបានដាក់វាហាលនៅលើខ្សែស្ទូខាងក្រោយផ្ទះ ។

ខ្ញុំបានដាក់ប្រាក់ប្រាំដុល្លាររបស់ខ្ញុំក្នុងហោប៉ៅខោខៅប៊ិយ ហើយប្រហែលជាអ្នកអាចទាយបានថា ខោខៅប៊ិយខ្ញុំត្រូវបានយកទៅដាក់នៅកន្លែងបោកអ៊ុតដោយមានប្រាក់នៅក្នុងហោប៉ៅខោនោះ ។ ពេលខ្ញុំបានដឹងនូវអ្វីដែលបានកើតឡើង ខ្ញុំមានការបារម្ភជាខ្លាំង ។ ខ្ញុំបានដឹងថា ជាទូទៅកន្លែងបោកអ៊ុតតែងស្ទាបមើលហោប៉ៅខោពីមុនដាក់បោក ។ បើប្រាក់ខ្ញុំមិនបានគេរកឃើញ ហើយមិនបានយកចេញនោះទេ នោះខ្ញុំបានដឹងច្បាស់ថា ប្រាក់នោះនឹងជ្រុះចេញពីហោប៉ៅអំឡុងពេលបោក ហើយនឹងត្រូវអ្នកធ្វើការម្នាក់ក្នុងកន្លែងបោកអ៊ុតនោះរើសបាន ដោយមិនបានដឹងថា ជាប្រាក់របស់នរណានោះទេ ទោះជាគាត់ចង់យកប្រាក់នោះទៅឲ្យម្ចាស់ដើមវិញយ៉ាងណាក្តី ។ ឱកាសទទួលបានប្រាក់ប្រាំដុល្លាររបស់ខ្ញុំមកវិញជារឿងមួយដ៏លំបាកបំផុត ---ជាអ្វីមួយដែលម្ដាយខ្ញុំបានគិតដូចគ្នា ពេលខ្ញុំបានប្រាប់គាត់ថា ខ្ញុំបានភ្លេចប្រាក់ក្នុងហោប៉ៅខោនោះ ។

ខ្ញុំចង់បានប្រាក់នោះ ខ្ញុំត្រូវការប្រាក់នោះ ខ្ញុំបានខិតខំធ្វើការដើម្បីរកប្រាក់នោះមក ។ ខ្ញុំបានដឹងថា មានរឿងតែម្យ៉ាងគត់ដែលខ្ញុំអាចធ្វើបាន ។ ដោយក្តីអស់សង្ឃឹមរបស់ខ្ញុំ ខ្ញុំបានងាកទៅរកព្រះវរបិតាខ្ញុំដែលគង់នៅស្ថានសួគ៌ ហើយទូលអង្វរទ្រង់ ដើម្បីជួយថែរក្សាប្រាក់ខ្ញុំឲ្យនៅក្នុងហោប៉ៅនោះ មិនថាដោយរបៀបណាទេ រហូតដល់ខោអាវរបស់យើងបានត្រឡប់មកវិញ ។

លុះពីរថ្ងៃក្រោយមក ពេលខ្ញុំបានដឹងថា ឡានដឹកជញ្ជូនខោអាវយើងបានជិតមកដល់ ខ្ញុំបានអង្គុយចាំនៅក្បែរបង្អួច ។ ពេលឡាននោះបានបើកចូលមកតែមថ្នល់ នោះបេះដូងខ្ញុំចាប់ផ្តើមលោត។ ពេលខោអាវទទឹកទាំងនោះ បានមកដល់ក្នុងផ្ទះមិនយូរប៉ុន្មាន ខ្ញុំក៏បានរើសខោខៅ  ប៊ិយខ្ញុំ ហើយរត់ចូលទៅក្នុងបន្ទប់ ។ខ្ញុំលូកចូលក្នុងហោប៉ៅនោះដោយដៃទាំងពីរញ័រ ។ រំពេចដែលពេលខ្ញុំលូកដៃឥតប៉ះអ្វីសោះ នោះខ្ញុំបានគិតថាអ្វីៗ បានបាត់អស់ហើយ ។ បន្ទាប់មក ដៃខ្ញុំបានប៉ះនឹងប្រាក់ប្រាំដុល្លារនោះ ។ ពេលខ្ញុំដកវាចេញពីហោប៉ៅមក នោះខ្ញុំមានអារម្មណ៍ថាបានធូរស្រាល ។ ខ្ញុំបានធ្វើការអធិស្ឋានដឹងគុណ ដោយអស់ពីចិត្តទៅកាន់ព្រះវរបិតាខ្ញុំដែលគង់នៅស្ថានសួគ៌ ពីព្រោះខ្ញុំបានដឹងថា ទ្រង់បានឆ្លើយតបការអធិស្ឋានរបស់ខ្ញុំ ។

ចាប់ពីពេលនោះមក ខ្ញុំបានទទួលចម្លើយចំពោះការអធិស្ឋានរាប់មិនអស់ ។ ខ្ញុំមិនដែលខកខានក្នុងការទំនាក់ទំនងជាមួយនឹងព្រះវរបិតាខ្ញុំដែលគង់នៅស្ថានសួគ៌ តាមរយៈការអធិស្ឋានមួយថ្ងៃណាឡើយ ។ វាជាទំនាក់ទំនងមួយ ដែលខ្ញុំឲ្យតម្លៃ ---ជាទំនាក់ទំនងមួយដែលខ្ញុំពិតជាត្រូវវង្វេង បើគ្មានវានោះ ។ ឥឡូវបើអ្នកមិនទាន់មានទំនាក់ទំនងមួយបែបនេះ ជាមួយនឹងព្រះវរបិតាអ្នក ដែលគង់នៅស្ថានសួគ៌ ខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យខិតខំឆ្ពោះទៅរកគោលដៅនោះ ។

ពេលអ្នកធ្វើដូច្នេះ អ្នកនឹងមានសិទ្ធិទទួលការបំផុសគំនិត និងការដឹកនាំទ្រង់ក្នុងជីវិតអ្នក ---ជាការចាំបាច់សម្រាប់យើងម្នាក់ៗ បើយើងចង់បន្តឲ្យមានភាពខាងវិញ្ញាណនៅក្នុងការធ្វើដំណើររបស់យើងលើផែនដីនេះ ។ ការបំផុសគំនិត និងការដឹកនាំបែបនោះ គឺជាអំណោយទានដែលទ្រង់ប្រទានឲ្យដោយសេរី យើងគ្រាន់តែស្វែងរកវាប៉ុណ្ណោះ ។ ឱ! វាជាទ្រព្យដ៏មានតម្លៃអ្វីម្ល៉េះ ។

ខ្ញុំតែងមានចិត្តរាបសា និងមានអំណរគុណ ពេលព្រះវរបិតាសួគ៌ខ្ញុំទំនាក់ទំនងជាមួយនឹងខ្ញុំ តាមរយៈការបំផុសគំនិតរបស់ទ្រង់នោះ ។ ខ្ញុំបានរៀនស្គាល់ រៀនទុកចិត្ត និងរៀនធ្វើតាមការណ៍នេះ ។ ម្តងហើយម្តងទៀត ខ្ញុំបានក្លាយជាអ្នកទទួលនូវការបំផុសគំនិតបែបនេះ ។ មានបទពិសោធន៍ដ៏រំភើបមួយ បានកើតឡើងក្នុងខែ សីហា ឆ្នាំ 1987 អំឡុងពេលការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធ ហ្វ្រែងហ្វើត អាល្លឺម៉ង់ ។ ប្រធាន អែសរ៉ា ថាហ្វ បែនសឹន បាននៅជាមួយយើងមួយ ឬពីរថ្ងៃនៃការឧទ្ទិសឆ្លងនោះ រួចលោកបានត្រឡប់ទៅផ្ទះវិញ ដូច្នេះហើយខ្ញុំត្រូវដឹកនាំសម័យប្រជុំដែលនៅសល់ ។

នៅថ្ងៃសៅរ៍ យើងមានសម័យប្រជុំមួយសម្រាប់សមាជិកជនជាតិហូឡង់ ដែលរស់នៅក្នុងមណ្ឌលព្រះវិហារបរិសុទ្ធ ហ្វ្រែងហ្វើត ។ ខ្ញុំបានស្គាល់អ្នកដឹកនាំដ៏ឆ្នើមម្នាក់មកពីប្រទេសហូឡង់ គឺបងប្រុស ភីទើរ ម៉ូរីក ។ ពីមុនសម័យប្រជុំនោះ មិនយូរប៉ុន្មានខ្ញុំមានអារម្មណ៍មួយដ៏ខុសប្លែកថា បងប្រុសម៉ូរីក  គួរតែត្រូវបានសុំឲ្យនិយាយទៅកាន់សមាជិករួមជាតិ    ហូឡង់របស់ខ្លួន នៅក្នុងសម័យប្រជុំនោះ ហើយថា គាត់គួរតែជាអ្នកនិយាយទីមួយ ។

ដោយមិនបានឃើញគាត់នៅក្នុងព្រះវិហារបរិសុទ្ធនាព្រឹកនោះ ខ្ញុំបានហុចសារយ៉ាងខ្លីមួយទៅឲ្យ អែលឌើរ ខាលូស អ៊ី អាស៊ី ជាប្រធានតំបន់របស់យើង ដោយសួរថាតើ ភីទើរ ម៉ូរីក អាចមកចូលរួមសម័យប្រជុំនោះដែរទេ ។

ពីមុនក្រោកឈរឡើងដើម្បីដឹកនាំសម័យប្រជុំនោះបន្តិច ខ្ញុំបានទទួលសារខ្លីមួយពី អែលឌើរ អាស៊ី ដោយបញ្ជាក់ថា តាមពិតបងប្រុស ម៉ូរីក *មិន* បានចូលរួមឡើយ ថាគាត់កំពុងជាប់រវល់នៅកន្លែងផ្សេងមួយទៀត ហើយថាគាត់មានគម្រោងនឹងចូលរួមក្នុងសម័យប្រជុំនៃការឧទ្ទិសឆ្លងក្នុងព្រះវិហារបរិសុទ្ធនៅថ្ងៃស្អែកជាមួយសមាជិកក្នុងជួរទ័ពប្រចាំស្តេក ។

ពេលខ្ញុំឈរនៅឯវេទិកាដើម្បីស្វាគមន៍ដល់មនុស្សទូទៅ និងដើម្បីរៀបរាប់ពីកម្មវិធីនោះ ខ្ញុំបានទទួលការបំផុសគំនិតយ៉ាងច្បាស់ជាថ្មីម្តងទៀតថា ខ្ញុំត្រូវប្រកាសថា ភីទើរ ម៉ូរីក ជាអ្នកនិយាយទីមួយ ។ រឿងនេះកាន់តែធ្វើឲ្យខ្ញុំមានការបារម្ភ ពីព្រោះខ្ញុំទើបតែបានឮពីអែលឌើរ អាស៊ី ថា បងប្រុស ម៉ូរីក នឹង *មិន* មកព្រះវិហារបរិសុទ្ធឡើយ ។ តែដោយទុកចិត្តលើការបំផុសគំនិតនោះ ខ្ញុំបានប្រកាសពីការសម្តែងរបស់ក្រុមចម្រៀង ការអធិស្ឋាន រួចហើយបានប្រាប់ថា អ្នកនិយាយទីមួយរបស់យើងគឺ បងប្រុស ភីទើរ ម៉ូរីក ។

ពេលខ្ញុំត្រឡប់មកកន្លែងអង្គុយវិញ ខ្ញុំបានមើលមុខ អែលឌើរ អាស៊ី ហើយបានឃើញពីទឹកមុខព្រួយបារម្ភរបស់គាត់ ។ ក្រោយមកគាត់បានប្រាប់ខ្ញុំថា ពេលខ្ញុំបានប្រកាសថា បងប្រុស ម៉ូរីក ជាអ្នកនិយាយទីមួយ នោះគាត់មិនចង់ជឿនឹងត្រចៀកឡើយ ។ គាត់បាននិយាយថា គាត់បានដឹងថាខ្ញុំបានទទួលសារគាត់រួចហើយ ហើយបានឃើញខ្ញុំអានវាទៀតផង ហើយគាត់មិនយល់សោះថាហេតុអ្វីបានជាខ្ញុំនៅតែប្រកាសបងប្រុស ម៉ូរីក ជាអ្នកឡើងនិយាយទៀត ដោយដឹងថាគាត់នឹងមិននៅក្នុងព្រះវិហារបរិសុទ្ធនោះឡើយ ។

អំឡុងពេលហេតុការណ៍នេះបានកើតឡើង ភីទើរ ម៉ូរីក  កំពុងនៅក្នុងការប្រជុំមួយនៅឯការិយាល័យប្រចាំតំបន់ក្នុង ភ័តត្រេស ។ ពេលការប្រជុំរបស់គាត់ចេះតែបន្តទៅមុខ រំពេចនោះគាត់បានងាកទៅរក អែលឌើរ ហ្វូគីស ដែលពេលនោះជាអ្នកតំណាងប្រចាំភូមិភាគ ហើយសួរថា « តើលោកអាចជូនខ្ញុំទៅព្រះវិហារបរិសុទ្ធយ៉ាងលឿនបំផុតដោយប្រើរយៈពេលប៉ុន្មាន ? »

អែលឌើរ ហ្វូគីស ដែលត្រូវបានគេស្គាល់ថា ជាអ្នកបើកឡានដ៏លឿនជាមួយនឹងឡានស្ព័ររបស់គាត់នោះ បានឆ្លើយថា « ខ្ញុំអាចជូនលោកដល់ទីនោះក្នុងរយៈពេល 10 នាទី !តែហេតុអ្វីបានជាលោកត្រូវទៅទីនោះ ? »

បងប្រុស ម៉ូរីក  បានសារភាពថា គាត់មិនបានដឹងពីហេតុផលដែលគាត់ត្រូវទៅទីនោះទេ តែគ្រាន់តែដឹងថា គាត់ត្រូវទៅដល់ទីនោះ ។ ពួកគេទាំងពីរនាក់ បានធ្វើដំណើរឆ្ពោះទៅកាន់ព្រះវិហារបរិសុទ្ធមួយរំពេច ។ អំឡុងពេលនៃការសម្តែងរបស់ក្រុមចម្រៀងដ៏ពិរោះ ខ្ញុំក្រឡេកមើលជុំវិញ ដោយគិតថា មិនយូរប៉ុន្មានខ្ញុំនឹងឃើញ ភីទើរ ម៉ូរីក  ។ តែខ្ញុំមិនបានឃើញគាត់ឡើយ ។ តែចម្លែកណាស់ គឺខ្ញុំគ្មានការបារម្ភអ្វីសោះ ។ ខ្ញុំមានការអះអាងដ៏ផ្អែមល្ហែម ហើយជាក់ច្បាស់មួយថា អ្វីៗនឹងបានប្រសើរឡើង ។

បងប្រុស ម៉ូរីក បានដើរចូរតាមច្រកទ្វារមុខនៃព្រះវិហារបរិសុទ្ធក្រោយពីការអធិស្ឋានបើកបានបញ្ចប់ ដោយមិនបានដឹងពីហេតុផលដែលគាត់ត្រូវទៅទីនោះនៅឡើយ ។ ពេលគាត់ប្រញាប់ប្រញាល់ចុះតាមច្រកដើរមកខាងក្រោម គាត់បានឃើញរូបខ្ញុំនៅលើអេក្រង់ ហើយបានឮខ្ញុំប្រកាសថា « ឥឡូវនេះយើងនឹងឮពីបងប្រុស ភីទើរ ម៉ូរីក » ។

រំពេចនោះ អែលឌើរ អាស៊ី មានការភ្ញាក់ផ្អើលជាខ្លាំង ពេលឃើញភីទើរ ម៉ូរីក បានដើរចូលមកក្នុងបន្ទប់ ហើយមកអង្គុយក្នុងកៅអីលើវេទិកា ។ ក្រោយពីសម័យប្រជុំនោះ បងប្រុស ម៉ូរីក ហើយនឹងខ្ញុំបានពិភាក្សាគ្នាពីអ្វីដែលបានកើតឡើងពីមុនគាត់ឡើងនិយាយ ។ ខ្ញុំបានពិចារណាថា ការបំផុសគំនិត ដែលកើតមាននៅថ្ងៃនោះ គឺមិនមែនសម្រាប់តែខ្ញុំម្នាក់ឯងនោះទេ តែវាក៏សម្រាប់បងប្រុស ភីទើរ ម៉ូរីក  ផងដែរ ។ បទពិសោធន៍ដ៏អស្ចារ្យនោះបានផ្តល់នូវសាក្សីមួយដ៏ពិតប្រាកដចំពោះខ្ញុំពីសារៈសំខាន់ នៃការមានភាពស័ក្តិសម ដើម្បីទទួលបានការបំផុសគំនិតបែបនេះ រួចហើយទុកចិត្តលើវា --- ហើយធ្វើតាមវា ---ពេលវាកើតមានឡើង ។ ខ្ញុំដឹងយ៉ាងច្បាស់ថា ព្រះអម្ចាស់ចង់ឲ្យអ្នកដែលចូលរួមក្នុងសម័យប្រជុំនោះ នៅក្នុងការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធ ប្រៃហ្វូងហ្វៀត បានស្តាប់ឮពីទីបន្ទាល់ដ៏អស្ចារ្យរបស់អ្នកបម្រើទ្រង់ គឺបងប្រុស ភីទើរ ម៉ូរីក  ។

បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំ ការទំនាក់ទំនងជាមួយនឹងព្រះវរបិតាសួគ៌យើងដែលគង់នៅស្ថានសួគ៌ ---រួមទាំងការអធិស្ឋានរបស់យើងទៅកាន់ទ្រង់ និងការបំផុសគំនិតរបស់ទ្រង់ ចំពោះយើងផងដែរ ---គឺជារឿងដ៏សំខាន់ ដើម្បីឲ្យយើង អាចស៊ូទ្រាំនឹងព្យុះភ្លៀង និងការសាកល្បងនៃជីវិត ។ ព្រះអម្ចាស់អញ្ជើញយើងថា « ចូរចូលមកជិតយើង នោះយើងនឹងចូលទៅជិតអ្នក ចូរព្យាយាមស្វែងរកយើង នោះអ្នករាល់គ្នានឹងបានជួបយើង » ។[7]

ពេលយើងធ្វើដូច្នេះ យើងនឹងទទួលអារម្មណ៍ពីព្រះវិញ្ញាណរបស់ទ្រង់ក្នុងជីវិតយើង ប្រទានឲ្យយើងនូវបំណងប្រាថ្នា និងភាពក្លាហាន ដើម្បីឈរយ៉ាងរឹងមាំក្នុងភាពសុចរិត --- ដើម្បី « ឈរនៅក្នុងទីបរិសុទ្ធទាំងឡាយ ហើយចូរកុំរើឡើយ » ។ [8]

ពេលពិភពលោកជុំវិញយើងមានការផ្លាស់ប្ដូរ ហើយយើងឃើញបទដ្ឋានសីលធម៌ក្នុងសង្គមមានការចុះខ្សោយ សូមឲ្យយើងចងចាំការសន្យាដ៏មានតម្លៃរបស់ព្រះអម្ចាស់ចំពោះអស់អ្នកដែលទុកចិត្តលើទ្រង់ថា ៖ « កុំឲ្យភ័យខ្លាចឡើយ ត្បិតយើងនៅជាមួយនឹងអ្នក កុំឲ្យស្រយុតចិត្តឲ្យសោះ ពីព្រោះយើងជាព្រះនៃអ្នក យើងនឹងចម្រើនកម្លាំងដល់អ្នក យើងនឹងជួយអ្នក យើងនឹងទ្រអ្នក ដោយដៃស្ដាំដ៏សុចរិតរបស់យើង » ។ [9]សូម ឲ្យពរជ័យទាំងនោះក្លាយជារបស់យើង ខ្ញុំសូមអធិស្ឋានក្នុងព្រះនាមដ៏ពិសិដ្ឋនៃព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះរបស់យើង ព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. Jonathan Sacks, *Wall Street Journal*, Aug. 20, 2011. Note: Lord Sacks is the chief rabbi of the United Hebrew Congregations of the Commonwealth.
2. និក្ខមនំ 20:3–4, 7, 8, 12–17 ។
3. មរ៉ូណៃ 8:18 ។
4. កូរិនថូសទី1 2:14 ។
5. អេសាយ 32:17 ។
6. នីហ្វៃទី3 18:18–20 ។
7. គោលលទ្ធិ និងសេចក្ដីសញ្ញា 88:63 ។
8. គោលលទ្ធិ និងសេចក្ដីសញ្ញា  87:8 ។
9. អេសាយ 41:10 ។